■ គម្រោងគាំទ្រពាណិជ្ជូបនីយកម្មស្រូវអង្ករកម្ពុជា [SCCRP]

[AFD Grant - CKH-1077-01-S និង CKH-1077-02-T]

AFD

ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ (SNEC)

កំណត់ត្រាគោលនយោបាយលេខ ៣

# ដំណើរការហិរញ្ញប្បទានសម្រាប់អង្គការកសិករ ក្នុងនាមជាតួអង្គសេដ្ឋកិច្ច និងពាណិជ្ជកម្មក្នុងខ្សែសង្វាក់តម្លៃ

ថ្ងៃទី ៣១ ខែមករា ឆ្នាំ ២០១៨

អ្នកនិពន្ធ៖ LAURENT LIAGRE, JEAN-MARIE BRUN, IRAM [1]

iram

## មាតិកា

១. បរិបទ និងសនិទានភាពនៃគោលនយោបាយប្រតិសកម្មស្តីពីដំណើរការហិរញ្ញប្បទានសម្រាប់អង្គការកសិករ ......២

២. បទពិសោធន៍របស់គម្រោង SCCRP ក្នុងការបង្កើតឥណទានដល់អង្គការកសិករ ......................................៣

៣. មេរៀនដំបូងស្តីពីសកម្មភាពរបស់ធានាគារអភិវឌ្ឍន៍ជនបទជាមួយអង្គការកសិករអំឡុងដំណាក់កាលសាកល្បង.៧

៤. ការផ្តល់អនុសាសន៍ផ្នែកគោលនយោបាយសម្រាប់ផ្តល់ហិរញ្ញប្បទានដល់អង្គការកសិករ............................ ១២

## អក្សរកាត់

| | |
|---|---|
| AC | សហករណ៍កសិកម្ម |
| AFD | *ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង* |
| AVSF | *អង្គការអ្នកក្សេត្រសាស្ត្រ និងពេទ្យសត្វគ្មានព្រំដែន* |
| CFAP | សហព័ន្ធសមាគមកសិករកម្ពុជានៃអ្នកផលិតកសិកម្ម |
| DACP | នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម (/MAFF) |
| FAEC | សហព័ន្ធសមាគមជំរុញសហគ្រាសកសិកម្មជាលក្ខណៈគ្រួសារនៅកម្ពុជា |
| FCFD | សហព័ន្ធអង្គការកសិករកម្ពុជាដើម្បីអភិវឌ្ឍន៍ |
| FI | គ្រឹះស្ថានហិរញ្ញវត្ថុ |
| FNN | បណ្តាញកសិករ និងធម្មជាតិ |
| FO | អង្គការកសិករ |
| FWN | បណ្តាញកសិករ និងទឹក |

| | |
|---|---|
| FWUC | សហគមន៍កសិករប្រើប្រាស់ទឹក |
| IRAM | *វិទ្យាស្ថានស្រាវជ្រាវនិងអនុវត្តវិធីសាស្ត្រអភិវឌ្ឍន៍* |
| MAFF | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| MEF | ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ |
| MFI | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ |
| NF3 | វេទិកាសហព័ន្ធអង្គការកសិករថ្នាក់ជាតិ |
| RDB | ធនាគារអភិវឌ្ឍន៍ជនបទ |
| SNEC | ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ |
| SCCRP | គម្រោងគាំទ្រពាណិជ្ជូបនីយកម្មស្រូវអង្ករកម្ពុជា |
| SCM | វិធីសាស្ត្រនៃដំណើរការក្នុងការផ្តល់ពិន្ទុ |

SCCRP ▪ កំណត់ត្រាគោលនយោបាយ

ការបដិសេធ: ឯកសារនេះបង្ហាញតែមតិរបស់អ្នកនិពន្ធដែលមិនមែនជាទស្សនះរបស់ AFD ឬ SNEC ទេ

[1] www.iram-fr.org

# ១. បរិបទ និងសនិទានភាពនៃគោលនយោបាយប្រតិសកម្មស្តីពីដំណើរការហិរញ្ញប្បទានសម្រាប់អង្គការកសិករ

## ១.១. ការបង្កើតអង្គការកសិករវិជ្ជាជីវៈដែលចូលរួមក្នុងខ្សែសង្វាក់តម្លៃ៖ គោលដៅនយោបាយខ្លាំង

ការបង្កើតសហគមន៍/អង្គការកសិករវិជ្ជាជីវៈដែលមានសមត្ថភាព គឺជាចំណុចគោលសំខាន់មួយនៃគោលនយោបាយអភិវឌ្ឍន៍របស់កម្ពុជា។ ឧទាហរណ៍៖ "ការលើកទឹកចិត្ត និងការគាំទ្រឱ្យមានការចូលរួមពីកសិករ និងអង្គការកសិករ(/សហគមន៍) ដើម្បីការពារផលប្រយោជន៍របស់ខ្លួន ដោយបង្កើតបរិយាកាសងាយស្រួលសម្រាប់បង្កើនផលិតកម្ម និងការផ្គត់ផ្គង់ស្រូវមានគុណភាពខ្ពស់ រាប់បញ្ចូលទាំងការលើកកម្ពស់អំណាចតថ្លៃរបស់កសិករលើការចរចាតម្លៃ" គឺជាគោលការណ៍មួយក្នុងចំណោមគោលការណ៍ចម្បងនានា ដែលមានចែងក្នុងឯកសារគោលនយោបាយស្តីពីការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ ដែលអនុម័តដោយទីស្តីការគណៈរដ្ឋមន្ត្រី នៅថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ ២០១០ ។

ការបង្កើត និងការគាំទ្រដល់សហគមន៍កសិកម្ម ក៏ជាស្នូលសំខាន់មួយនៃយុទ្ធសាស្ត្ររបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទផងដែរ។ ផែនការសកម្មភាពរបស់ក្រសួងសម្រាប់អនុវត្តឯកសារគោលនយោបាយស្តីពីការជំរុញផលិតកម្ម និងការផ្គត់ផ្គង់ស្រូវ គឺរាប់បញ្ចូលនូវគោលនយោបាយដែលកំណត់អំពី "ការពង្រឹងសមត្ថភាពកសិករ និងសហគមន៍កសិកម្ម ដើម្បីការពារ និងប្រើប្រាស់ប្រាក់កម្ចីពីគ្រឹះស្ថានហិរញ្ញវត្ថុ (FI) ប្រកបដោយប្រសិទ្ធភាព"។

សហគមន៍កសិកម្ម (ជារួមហៅថា អង្គការកសិករ)[2] អាចដើរតួនាទីជាក់លាក់មួយនៅក្នុងពាណិជ្ជូបនីយកម្មផលិតផលកសិកម្ម ក៏ដូចជាការផ្គត់ផ្គង់ធាតុចូល និងការពង្រឹងការទទួលបានព័ត៌មាន និងអំណាចតថ្លៃរបស់កសិករ ដោយសារពួកគេពាក់ព័ន្ធនឹងបរិមាណទំនិញដ៏ច្រើន និងអាចទាក់ទងដោយផ្ទាល់ជាមួយអ្នកលក់ដុំ ឬកសិឧស្សាហកម្មធំៗ ជំនួសឱ្យការទាក់ទងជាមួយអ្នកលក់រាយ ឬឈ្មួញកណ្តាលនៅក្នុងមូលដ្ឋាន។

## ១.២. ដំណើរការហិរញ្ញប្បទានរបស់អង្គការកសិករ / សហគមន៍៖ បញ្ហារាំងស្ទះចម្បង

ដើម្បីអភិវឌ្ឍឱ្យបានពេញលេញ គឺតួនាទីនៃការចូលរួមរបស់អង្គការកសិករក្នុងនាមជាតួអង្គពាណិជ្ជកម្មក្នុងខ្សែសង្វាក់តម្លៃ អាចតម្រូវឱ្យអង្គការកសិករមានសមត្ថភាពហិរញ្ញវត្ថុជាក់លាក់សម្រាប់ការវិនិយោគ ឬយ៉ាងហោចណាស់មានមូលធនប្រតិបត្តិការ។ ដូច្នេះ **ដំណើរការហិរញ្ញប្បទានជាបញ្ហារាំងស្ទះចម្បងសម្រាប់ការអភិវឌ្ឍសមត្ថភាពផ្នែកពាណិជ្ជកម្មរបស់សហគមន៍កសិកម្ម**។ ជាទូទៅ ទុនរបស់សហគមន៍នៅមានកម្រិតខ្លាំង ហើយភាគច្រើនមិន (ឬមានកម្រិតខ្លាំង) ទទួលបានកម្ចី[3]ពីធនាគារ ឬគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុផ្លូវការទេ ដោយសារកង្វះទ្រព្យសកម្មដែលសហគមន៍អាចប្រើជាប្រាតិភោគ។ ក្រៅពីនេះ ទោះបីជាសហគមន៍អាចទទួលបានប្រាក់កម្ចីពីធនាគារ ឬគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុក៏ដោយ ក៏បន្ទុកចំណាយហិរញ្ញវត្ថុ (ជាពិសេស អត្រាការប្រាក់) នៅតែមានកម្រិតខ្ពស់ដដែល (ជាទូទៅ ការផ្តល់ប្រាក់កម្ចីដល់សហគ្រាសខ្នាតតូច និងមធ្យម មានការប្រាក់ប្រហែលពី ១ ទៅ ១,៥ % ក្នុងមួយខែ និងសម្រាប់កម្ចីមូលធនគឺនៅចន្លោះប្រហែល ១០ ០០០ ទៅ ៣០ ០០០ ដុល្លារអាមេរិក)...

[2] សហករណ៍កសិកម្មត្រូវចុះបានបញ្ជីដោយក្រសួងកសិកម្ម ហើយបច្ចុប្បន្នស្ថិតនៅក្នុងគម្រោងច្បាប់ស្តីពីសហករណ៍កសិកម្ម ឆ្នាំ ២០១៣ ។ អង្គការកសិករត្រូវបានគេយល់យ៉ាងទូលំទូលាយថាជា ប្រភេទអង្គការកសិករណាមួយ (មិនមែនយោងតាមក្របខណ្ឌច្បាប់ជាក់លាក់ទេ) ហើយពាក្យនេះអាចរាប់បញ្ចូលទាំង សហករណ៍កសិកម្ម សមាគម សហគមន៍កសិករប្រើប្រាស់ទឹក។ល។

[3] សហករណ៍កសិកម្មមានសិទ្ធិស្របច្បាប់ក្នុងការទទួលបានឥណទាន ប៉ុន្តែបទប្បញ្ញត្តិច្បាប់អាចកម្រិតលើផលធៀបរវាងបរិមាណឥណទានសរុបដែលពួកគេទទួលបានទៅនឹងមូលធនដែលគេមាន។

ផ្ទុយទៅវិញ ម្ចាស់រោងម៉ាស៊ីនកិនស្រូវទទួលបានប្រាក់កម្ចី (ជាពិសេស ប្រាក់កម្ចីដែលផ្តល់ដោយធនាគារអភិវឌ្ឍន៍ជនបទ – RDB) មានអត្រាការប្រាក់ចំនួនពី ៦ ទៅ ៩%/ឆ្នាំ។ តាមការជាក់ស្តែង ម្ចាស់រោងម៉ាស៊ីនកិនស្រូវទំនងជាខ្ចីប្រាក់បានច្រើន និងអាចផ្តល់ប្រាតិភោគខ្លាំងជាង។ ភាពខុសគ្នានៃការទទួលបានហិរញ្ញប្បទាននេះបង្កើតបានភាពខុសគ្នាខាងអំណាចតថ្លៃរវាងម្ចាស់រោងម៉ាស៊ីនកិនស្រូវ និងសហករណ៍។ កសិករអាចទទួលបានឥណទានសម្រាប់ការផ្គត់ផ្គង់ធាតុចូល (ដូចជាគ្រាប់ពូជ និងជី) ពីម្ចាស់រោងម៉ាស៊ីនកិនស្រូវ ឬពីអ្នកប្រមូលទិញស្រូវក្នុងភូមិ ប៉ុន្តែបន្ទាប់មកអាច "ជាប់ផុង" ដោយ**កត្តាពឹងផ្អែកផ្នែកហិរញ្ញវត្ថុនេះបានបន្ថយនូវអំណាចតថ្លៃលើតម្លៃស្រូវរបស់កសិករ ដែលវាផ្ទុយនឹងគោលការណ៍ដែលមានចែងក្នុងឯកសារគោលនយោបាយ**ស្តីពីការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ។

**ប្រសិនបើគ្មានដំណើរការហិរញ្ញប្បទានទេ នោះសហករណ៍កសិកម្មមិនអាចដំណើរការចាប់ពីដំណាក់កាលដំបូងនៃការបង្កើតរបស់ខ្លួន គឺដំណាក់កាលសហគមន៍ខ្នាតតូចនៅកម្រិតភូមិទៅជាដំណាក់កាលសហគមន៍ខ្នាតមធ្យម ដែលអាចធ្វើសកម្មភាពនៅកម្រិត SME បានឡើយ។ ហើយក្រោយមក គោលដៅក្នុងការឱ្យសហគមន៍ច្របាច់បញ្ចូលគ្នាជាតួអង្គពាណិជ្ជកម្មរឹងមាំនៅក្នុងសង្វាក់តម្លៃ នៅតែស្ថិតនៅក្នុងការពិចារណាដដែល។ បន្ថែមពីនេះ ចំពោះអ្នកដែលទទួលបានធនធានក្នុងតម្លៃដូចគ្នានឹងម្ចាស់រោងម៉ាស៊ីនកិនស្រូវ ត្រូវបង់អត្រាការប្រាក់លើប្រាក់កម្ចីរបស់ខ្លួន។**

# ២. បទពិសោធន៍របស់គម្រោង SCCRP ក្នុងការបង្កើតឥណទានដល់អង្គការកសិករ

## ២.១. បទពិសោធន៍សាកល្បងនៃឥណទានរបស់ធនាគារអភិវឌ្ឍន៍ជនបទ ដែលផ្តល់ឱ្យអង្គការកសិករ

ដើម្បីដោះស្រាយបញ្ហាការផ្តល់ហិរញ្ញប្បទានដល់អង្គការកសិករ និងកែលម្អភាពទាក់ទងគ្នារវាងគោលដៅនយោបាយ និងឧបករណ៍ដែលប្រើប្រាស់តាមរយៈធនាគារអភិវឌ្ឍន៍ជនបទដែលជាកម្មសិទ្ធិរបស់រដ្ឋ នោះគម្រោង SCCRP បានគាំទ្រដល់ការបង្កើតឱ្យមានការផ្តល់ហិរញ្ញប្បទានថ្មីមួយពីធនាគារអភិវឌ្ឍជនបទដល់អង្គការកសិករ។

ការផ្តល់ឥណទាននេះត្រូវបានអនុម័តនៅខែមិថុនា ឆ្នាំ ២០១៦ ។ លក្ខណៈពិសេសចម្បងនៃផលិតផលហិរញ្ញប្បទានដែលបានស្នើនេះមានពណ៌នាក្នុងប្រអប់លេខ ១ នៅទំព័របន្ទាប់។

យន្តការឥណទាននេះត្រូវបានអនុវត្តនៅក្នុងដំណាក់កាលសាកល្បងចាប់ពីពេលនោះមកម្ល៉េះ។ បញ្ហាប្រឈមដែលត្រូវដោះស្រាយ គឺការបែងចែកឥណទាន ពីព្រោះតែធនាគារអភិវឌ្ឍជនបទមិនមានការិយាល័យសាខារបស់ខ្លួននៅតាមបណ្តាខេត្តទេ។ ដើម្បីដោះស្រាយបញ្ហានេះបាន ភាពជាដៃគូមិនផ្លូវការមួយត្រូវបានបង្កើតឡើងដោយធនាគារអភិវឌ្ឍជនបទ និងសហព័ន្ធអង្គការកសិករចំនួនពីរ (FAEC និង FCFD)។ សហព័ន្ធទាំងពីរនេះបានបញ្ជូនព័ត៌មានអំពីការផ្តល់ឥណទានរបស់ធនាគារអភិវឌ្ឍជនបទទៅដល់សមាជិករបស់ខ្លួន ជាពិសេសតាមរយៈសិក្ខាសាលានានានៅថ្នាក់ខេត្ត (ក្នុងករណីមួយចំនួន សិក្ខាសាលានេះរៀបចំឡើងដោយមានវត្តមានរបស់មន្ត្រីឥណទានម្នាក់មកពីធនាគារអភិវឌ្ឍជនបទ)។ បន្ទាប់ពីផ្តល់ព័ត៌មានអំពីស្ថានភាពដែលធនាគារអភិវឌ្ឍជនបទបានស្នើរួចហើយ សហព័ន្ធបានធ្វើការកំណត់អត្តសញ្ញាណអង្គការកសិករ/សហករណ៍ ដែលមានបំណងបង្កើតសកម្មភាពពាណិជ្ជកម្ម (ករណីភាគច្រើនបំផុតគឺសម្រាប់ការផ្គត់ផ្គង់ធាតុចូល ឬពាណិជ្ជូបនីយកម្មផលិតផលកសិកម្ម) និងដែលអាចត្រូវការសេវាហិរញ្ញប្បទាន។ បន្ទាប់មក ពួកគេបានផ្តល់ជំនួយដល់អង្គការកសិករទាំងនេះក្នុងការត្រៀមរៀបចំផែនការអាជីវកម្ម និងការដាក់ពាក្យស្នើសុំ

ឥណទាន ព្រមទាំងការដាក់ពាក្យស្នើសុំនទៅធនាគារអភិវឌ្ឍជនបទ។ ក្នុងករណីមួយចំនួន ចំពោះអង្គការកសិករដែលគេចាត់ទុកថាសមត្ថភាពគ្រប់គ្រងនៅខ្សោយខ្លាំង នោះសហព័ន្ធអាចលើកទឹកចិត្តពួកគេដោយពន្យារពេលគម្រោងរបស់ខ្លួន និងពង្រឹងសមត្ថភាព និងបទពិសោធន៍របស់ខ្លួនជាដំបូងនៅកម្រិតតូច មុនពេលពិចារណាលើការបង្កើនកម្ចី។ បន្ទាប់ពីអនុវត្តបានមួយឆ្នាំកន្លះ ធនាគារអភិវឌ្ឍន៍ជនបទបានទទួលពាក្យស្នើសុំចំនួន ១៤ ពីសហករកសិកម្ម និងបានអនុញ្ញាតផ្តល់ប្រាក់កម្ចីចំនួន ៧ លើកដែលមានទឹកប្រាក់សរុបចំនួន ៧៤ ០០០ ដុល្លារ (សូមមើលតារាងទី ១)។

**តារាងទី ១៖ របាយការណ៍ស្តីពីពាក្យស្នើសុំដែលធនាគារអភិវឌ្ឍន៍ជនទទួលបានពីអង្គការកសិករ និងប្រាក់កម្ចីដែលមានការយល់ព្រមផ្តល់ឱ្យ (ចាប់តាំងពីការអនុម័តគោលនយោបាយឥណទានថ្មីរបស់ធនាគារអភិវឌ្ឍន៍ជនបទទៅលើអង្គការកសិករនៅខែមិថុនា ឆ្នាំ ២០១៦ និងនៅខែធ្នូ ឆ្នាំ ២០១៧)**

| លេខ | ឈ្មោះ AC | ខេត្ត | កាលបរិច្ឆេទនៃការដាក់បញ្ជូនសំណើ | សមាជិកនៃ | ពិន្ទុ SCM | ចំនួនប្រាក់កម្ចីដែលបានស្នើ | ប្រភេទអាជីវកម្ម | ប្រភេទវត្ថុបញ្ចាំ | សេចក្តីសម្រេច RDB | ការតម្កល់ប្រាក់ធានា | ប្រាក់កម្ចីដែលបានព្រមទទួល | ដើមទុនដែលបានសង |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ១ | សាមគ្គី រិទ្ធីតាអ៊ុង | ព្រៃវែង | ៣០ សីហា ១៦ | FCFD | ៧៨ | $ ៥០០០ | ពាណិជ្ជកម្មជី | ប្លង់រឹង | គ្មាន | | | |
| ២ | ពន្លឺ សាមគ្គី | ព្រៃវែង | ៣០ សីហា ១៦ | FCFD | ៧៣ | $ ៥០០០ | ពាណិជ្ជកម្មជី | ប្លង់រឹង | គ្មាន | | | |
| ៣ | មានជ័យ ព្រះបាត្តំ មានជ័យ | ព្រៃវែង | ១៤ កញ្ញា ១៦ | FCFD | ៦៨ | $ ៥០០០ | ពាណិជ្ជកម្មជី | ប្លង់រឹង | មាន | មាន (៤០%) | $ ៥០០០ | $ ៥០០០ ✓ |
| ៤ | សហគមន៍ ក្សីកាម សាមគ្គី ថ្កូវ | ព្រៃវែង | ១៤ កញ្ញា ១៦ | FCFD | ៦២ | $ ៥០០០ | ពាណិជ្ជកម្មជី | ប្លង់រឹង | គ្មាន | | | |
| ៥ | ចម្រើន ផល រាំង គីសី | បាត់ដំបង | ២០ កញ្ញា ១៦ | FAEC | ៨៧ | $ ៩០៧០ | ពាណិជ្ជកម្មអង្ករ | ប្លង់ទន់ | មាន | មាន (៥០%) | $ ៦០០០ | $ ៦០០០ ✓ |
| ៦ | ត្រពាំងឫស្សី | កំពង់ធំ | ១៧ តុលា ១៦ | FCFD | ៨៩ | $ ៣០០០ | ពាណិជ្ជកម្មស្រូវ+គ្រាប់ពូជ | ប្លង់រឹង | គ្មាន | | | |
| ៧ | ឧត្តម សុរិយា | តាកែវ | ២០ មីនា ១៧ | FAEC | ៨៣ | $ ៧០០០ | ពាណិជ្ជកម្មអង្ករ | ប្លង់ទន់ | មាន | គ្មាន | $ ៧០០០ | |
| ៨ | បក្សី រាក្រាយ | តាកែវ | ២០ មីនា ១៧ | FAEC | ៦៦ | $ ២០០០ | ពាណិជ្ជកម្មអង្ករ&ជី កិន | ប្លង់ទន់ | មាន | គ្មាន | $ ១១០០០ | |
| ៩ | ត្រពាំង ក្រាន់ហួង | តាកែវ | ២៣ មីនា ១៧ | FCFD | ៩០ | $ ១០០០០ | ពាណិជ្ជកម្មអង្ករ&ជី | ប្លង់ទន់ | មាន | គ្មាន | $ ១០០០០ | |
| ១០ | ស័ង្កហាក់ កសិករ សាំ យ៉ុង | ស្វាយរៀង | ២៤ មីនា ១៧ | FAEC | ៧១ | $ ១៥០០០ | ពាណិជ្ជកម្មអង្ករ&ជី កិន | ប្លង់ទន់ | គ្មាន | | | |
| ១១ | ភ្នំ ក្រាពី AC | បាត់ដំប | ១៣ កក្កដា ១៧ | FAEC | | $ ៥០០០ | ពាណិជ្ជកម្មអង្ករ&ជី គ្រាប់ពូជ | ប្លង់ទន់ | គ្មាន | | | |
| ១២ | កំពង់ស្ពឺ ស៊ូហ្គើ P | កំពង់ស្ពឺ | ៩ តុលា ១៧ | FAEC | ៨១ | $ ៣០០០០ | ពាណិជ្ជកម្មជីស្ករស និងទិញជណ្តើរខ្ពស់ | ប្លង់ទន់ | មាន | គ្មាន | $ ២០០០០ | |
| ១៣ | ត្រពាំង ឫសស្សី | កំពង់ធំ | ១៦ វិច្ឆិកា ១៧ | FCFD | ៨៩ | $ ២០០០០ | ពាណិជ្ជកម្មស្រូវ+គ្រាប់ពូជ | ប្លង់រឹង | មាន | គ្មាន | $ ១៥០០០ | |
| ១៤ | សំបូរមាសមាន C១ | កំពង់ធំ | ១៦ វិច្ឆិកា ១៧ | FCFD | ៦២ | $ ៥០០០ | ពាណិជ្ជកម្មជី | ប្លង់ទន់ | គ្មាន | | | |

នៅក្នុងការអនុវត្តដំណាក់កាលដំបូង ដំណើរការការវាយតម្លៃលើការដាក់ពាក្យស្នើសុំប្រាក់កម្ចីគឺត្រូវការពេលវេលាច្រើនសមល្មមដែរ។ ត្រង់ចំណុចនេះពន្យល់គឺបានខ្លះថាអត្រាជោគជ័យនៃការដាក់ពាក្យស្នើសុំខ្ចីប្រាក់ដែលធនាគារអភិវឌ្ឍន៍ជនបទបានទទួលគឺមានតិចតួចកាលពីឆ្នាំ ២០១៦ (ពាក្យស្នើសុំខ្ចីប្រាក់មួយចំនួនគឺមានការដកចេញវិញដោយសារតែធនាគារអភិវឌ្ឍន៍ជនបទមិនបានសម្រេចចិត្តទាន់ពេលវេលាសម្រាប់សកម្មភាព (តាមរដូវកាល) ថាត្រូវអនុវត្ត ឬប្រានចោល)។ កាលពីឆ្នាំ ២០១៧ នីតិវិធីនៅក្នុងធនាគារអភិវឌ្ឍន៍ជនបទមានការកែលម្អ ហើយការពន្យាពេលលើការសម្រេចចិត្តត្រូវក៏មានការកែតម្រូវដែរ (ប៉ុន្តែនៅតែមានរយៈពេលយូរ៖ ប្រហែលមួយខែ ហើយបើតាមគោលដៅគឺនឹងកាត់បន្ថយបន្ថែមសល់ត្រឹម ២ - ៣ សប្តាហ៍)។

ក្នុងករណីខ្លះ ដើម្បីកាត់បន្ថយលក្ខខណ្ឌដាក់វត្ថុបញ្ចាំ គឺមានការប្រើប្រាស់ការធានាឥណទាន។ នៅដំណាក់កាលសាកល្បង សម្រាប់ប្រាក់កម្ចីចំនួនពីរលើកដំបូង គឺគម្រោង SCCRP បានផ្តល់ការធានាដោយផ្ទាល់។ ទន្ទឹមនឹងនេះ គម្រោងនេះ គឺកំពុងធ្វើការជាមួយនឹងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីបង្កើតយន្តការធានាលក្ខណៈស្ថាប័នមួយដែលអាច (ជាផ្នែក) ប្រើប្រាស់ ដើម្បីធានាឥណទានដល់អង្គការកសិកររយៈពេលវែង (សូមមើលប្រអប់ទី ២ ៖ ការបង្កើតយន្តការធានាឥណទាន)។

## ប្រអប់ទី ១៖ ការផ្តល់ឥណទានរបស់ធនាគារអភិវឌ្ឍន៍ជនបទដល់អង្គការកសិករ

**គោលដៅ៖** ជាឥណទានដើម្បីផ្តល់ហិរញ្ញប្បទានដល់សកម្មភាពពាណិជ្ជកម្មរបស់សហករកសិកម្ម ឬអង្គការកសិករដែលបានចុះបញ្ជីតាមច្បាប់ត្រឹមត្រូវ។

**លក្ខខណ្ឌអប្បបរមា៖**

- បានចុះបញ្ជីត្រឹមត្រូវជាសហករកសិកម្មជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឬជាមួយនឹងអង្គការកសិករផ្សេងទៀតបែបនីតិបុគ្គល;
- មានបទពិសោធន៍យ៉ាងហោចណាស់មួយឆ្នាំលើសកម្មភាពពាណិជ្ជកម្ម;
- អាចផ្តល់ព័ត៌មានហិរញ្ញប្បទានបាន រួមបញ្ចូលទាំងទ្រព្យសកម្ម បំណុល ដើមទុន ប្រាក់ចំណូល និងចំណាយ
- មានវត្ថុបញ្ចាំ (អចលនទ្រព្យ);

**លក្ខខណ្ឌប្រាក់កម្ចីរយៈពេលខ្លី៖**

- សម្រាប់ប្រាក់តម្រូវការដើមទុនការងារ
-ប្រាក់កម្ចីអប្បបរមាចំនួន ៥០០០ ដុល្លារអាមេរិក (ក្នុងមួយសហករ ហើយមិនត្រូវការមានពាក្យស្នើសុំប្រាក់កម្ចីបែបពហុភាគី ច្រើនក្រុមទេ)
- ប្រាក់កម្ចីអតិបរមាចំនួន ៥០០០០ ដុល្លារអាមេរិក

- ចំនួនប្រាក់កម្ចីចុងក្រោយនឹងត្រូវពឹងផ្អែកតាមលំហូរសាច់ប្រាក់ពីមុន និងដែលបានគ្រោងទុករបស់សហករ ហើយមិនត្រូវមានចំនួនធំជាងទុនរបស់សហករចំនួន ៤ ដង ហើយនឹងមិនត្រូវមានចំនួនធំជាងប្រាក់តម្រូវការដើមទុនការងារចំនួន ៨០% ឡើយ។
- រយៈពេលមិនលើសពី ១២ ខែ
- ការប្រាក់ ១០,៥% សម្រាប់ប្រាក់កម្ចីលុយដុល្លារ និង ៣% បន្ថែមទៀតសម្រាប់ប្រាក់កម្ចីលុយរៀល (បានគិតបញ្ចូលថ្លៃសេវាកម្ម និងថ្លៃធានា)
- ការសងប្រាក់ដើមវិញ អាចធ្វើឡើងដោយសងទាំងអស់នៅពេលដល់ការកំណត់ ឬបង់រំលស់អាស្រ័យលើប្រភេទនៃអាជីវកម្ម និងលំហូរសាច់ប្រាក់; ការប្រាក់ត្រូវបង់ជាប្រចាំខែ;
- ការបង់ប្រាក់យឺតយ៉ាវលើសរយៈពេល ១៥ ថ្ងៃ អាចនឹងត្រូវបង់ផាកពិន័យការប្រាក់ទ្វេគុណ

**លក្ខខណ្ឌប្រាក់កម្ចីរយៈពេលវែង/ប្រាក់កម្ចីវិនិយោគទុន**

- សម្រាប់ប្រាក់វិនិយោគទុនលើអចលនទ្រព្យ គ្រឿងយន្ត ឧបករណ៍សម្រាប់ប្រើប្រាស់នៅក្នុងសកម្មភាពពាណិជ្ជកម្ម
- ប្រាក់កម្ចីអប្បបរមាមានចំនួន ១០០០០ ដុល្លារអាមេរិក (រយៈពេល ១-៥ ឆ្នាំ ដែលរួមបញ្ចូលរយៈពេលជម្រើសអនុគ្រោះរហូតដល់ ១ ឆ្នាំ។)
- ប្រាក់កម្ចីអតិបរមាមានចំនួន ១០០០០០ ដុល្លារអាមេរិក
- ចំនួនប្រាក់កម្ចីចុងក្រោយនឹងត្រូវពឹងផ្អែកតាមលំហូរសាច់ប្រាក់ពីមុន និងដែលបានគ្រោងទុករបស់សហករ ហើយមិនត្រូវមានចំនួនធំជាងទុនរបស់សហករចំនួន ៤ ដង ហើយនឹងមិនត្រូវមានចំនួនធំជាងប្រាក់វិនិយោគទុនដែលបានគ្រោងទុកចំនួន ៨០% ឡើយ។
- រយៈពេល ១-៥ ឆ្នាំ ដែលរួមបញ្ចូលរយៈពេលជម្រើសអនុគ្រោះរហូតដល់ ១ ឆ្នាំ។
- ការប្រាក់ចំនួន ១០ % សម្រាប់ប្រាក់កម្ចីលុយដុល្លារ និង ៣% បន្ថែមទៀតសម្រាប់ប្រាក់កម្ចីលុយរៀល (បានគិតបញ្ចូលថ្លៃសេវាកម្ម និងថ្លៃធានា)
- ការសងដើមវិញអាចធ្វើឡើងដោយបង់រំលស់ប្រចាំត្រីមាស ឬជាឆមាសជាងរៀងរាល់ឆ្នាំ ដោយផ្អែកទៅតាមប្រភេទនៃជំនួញ និងលំហូរសាច់ប្រាក់; ការប្រាក់នឹងត្រូវបង់ជាប្រចាំខែ។
- ការបង់ប្រាក់យឺតយ៉ាវលើសរយៈពេល ១៥ ថ្ងៃ អាចនឹងត្រូវបង់ផាកពិន័យការប្រាក់ទ្វេគុណ

**វត្ថុបញ្ចាំ (សម្រាប់ប្រាក់កម្ចីរយៈពេលខ្លី និងរយៈពេលវែង និងសម្រាប់អតិថិជនថ្មី និងចាស់)៖**

- វត្ថុបញ្ចាំមានទម្រង់ជាអចលនទ្រព្យ លិខិតធានា បញ្ញើមានកាលកំណត់ មាស ឧបករណ៍ និងសាពើភ័ណ្ឌ (វត្ថុ ២ ដែលបានបង្ហាញនៅខាងក្រោយនេះគឺមានភាពលំបាកក្នុងការអនុវត្តនៅពេលបច្ចុប្បន្ននេះ);
- វត្ថុបញ្ចាំមិនមែនអចលនទ្រព្យអាចនឹងត្រូវការការធានាលើថ្លៃវត្ថុបញ្ចាំទៅដល់ចំនួន ៣០%;
- សម្រាប់ប្រាក់កម្ចីមានតម្លៃប្លង់ទន់តិចជាង ១០០០០ ដុល្លារអាមេរិកគឺគ្រប់គ្រាន់;
- ផលធៀបតម្លៃប្រាក់កម្ចីលើវត្ថុបញ្ចាំ គឺមានចំនួន ៧០% សម្រាប់អចលនទ្រព្យដែលមានទីតាំងស្ថិតនៅក្នុងទីក្រុង/ខេត្ត ដែលមានហាងនៅពីមុខ រោងចក្រ អគារឧស្សាហកម្ម ឬអគារលំនៅដ្ឋាន;
- ផលធៀបតម្លៃប្រាក់កម្ចីលើវត្ថុបញ្ចាំ គឺមានចំនួន ៦០% សម្រាប់អចលនទ្រព្យដែលស្ថិតនៅក្រៅទីក្រុង/ខេត្ត ប៉ុន្តែមានហាងនៅពីមុខ រោងចក្រ អគារឧស្សាហកម្ម ឬអគារលំនៅដ្ឋាន;

- ផលធៀបតម្លៃប្រាក់កម្ចីលើវត្ថុបញ្ចាំគឺមានចំនួន ៥០% សម្រាប់អចលនទ្រព្យដែលអំណោយផលដល់ការធ្វើកសិកម្ម
- មូលនិធិធានាអាចនឹងត្រូវយកមកប្រើប្រាស់ដើម្បីបង្កើនផលធៀបតម្លៃប្រាក់កម្ចីលើវត្ថុបញ្ចាំលើសពីសមាមាត្រធៀបទៅនឹងចំនួននៃការធានាប្រាក់កម្ចីបាន។ ឧ. ដោយមានការធានា ៥០% ពីមូលនិធីធានាលក្ខខណ្ឌ ៥០% អាចនឹងបង្កើនទៅដល់ ៧៥% ។

**ប្រអប់ទី ២ ៖ ការបង្កើតយន្តការធានាឥណទាន**

ដូចបានបង្ហាញនៅក្នុងចំណុចចុងក្រោយនៃប្រអប់ទី ១ ខាងលើ ដោយសារមានការចាត់ទុកថាការប្រមូលវត្ថុបញ្ចាំឱ្យបានគ្រប់គ្រាន់គឺជាឧបសគ្គចម្បងសម្រាប់អង្គការកសិករ ដូចនេះយន្តការធានាគឺអាចត្រូវប្រើប្រាស់ដើម្បីបន្ថយ (ប៉ុន្តែមិនបោះបង់ចោលទាំងស្រុងទេ) លក្ខខណ្ឌវត្ថុបញ្ចាំសម្រាប់ការផ្តល់ប្រាក់កម្ចីដល់អង្គការកសិករ។

សម្រាប់ប្រាក់កម្ចីពីរលើកដំបូងដែលធនាគារអភិវឌ្ឍន៍ជនបទបានផ្តល់ជូនដោយស្ថិតក្រោមគម្រោងឥណទានថ្មីនេះ ប្រាក់កម្ចីទុនពី ៤០% ទៅ ៥០% គឺត្រូវមានការធានាផ្ទាល់ពីគម្រោង SCCRP ដែលជាដំណោះស្រាយបណ្តោះអាសន្ន ដើម្បីសាកល្បងការអនុវត្តមូលនិធិធានា។ បច្ចុប្បន្ននេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុកំពុងពិចារណាលើការបង្កើតមូលនិធិធានា ហើយមួយផ្នែកគឺអាចយកទៅធានា (នៅពេលចាំបាច់) លើប្រាក់កម្ចីដល់អង្គការកសិករ។ គេរំពឹងថាយន្តការធានានេះអាចត្រូវបង្កើតឡើងជាផ្លូវការនៅដើមឆ្នាំ ២០១៨ ។

គោលការណ៍ព្យាករណ៍នៃយន្តការធានានេះរួមមាន៖

- យោងទៅតាមគោលការណ៍បញ្ចាំរបស់គ្រឹះស្ថានហិរញ្ញវត្ថុ អ្នកខ្ចីត្រូវតែមានការតម្រូវឱ្យដាក់វត្ថុបញ្ចាំបន្ថែម (ដើម្បីបំពេញបង្គ្រប់បន្ថែមលើប្រាក់ធានា)។
- ករណីមានកំហុស មូលនិធិធានានេះនឹងគ្របដណ្តប់លើភាគរយនៃទុននៅសល់ក្នុងកិច្ចសន្យា គិតត្រឹមកាលបរិច្ឆេទនៃការទាមទារ ។
- ការខាតបង់ទាំងអស់នឹងត្រូវរួមគ្នាខាត។

- រាល់ប្រាក់ដែលបានប្រមូល នៅមុន និងក្រោយការទូទាត់ពីមូលនិធិធានានឹងត្រូវចែករំលែករវាងមូលនិធិធានា និងគ្រឹះស្ថានហិរញ្ញវត្ថុតាមសមាមាត្រនៃភាគរយដែលបានព្រមព្រៀងគ្នាដែលមាននៅក្នុងលិខិតផ្តល់ប្រាក់ធានា។

# ៣. មេរៀនដំបូងស្តីពីសកម្មភាពរបស់ធានាគារអភិវឌ្ឍន៍ជនបទជាមួយអង្គការកសិករអំឡុងដំណាក់កាលសាកល្បង

ដំណាក់កាលសាកល្បងដែលគាំទ្រដោយគម្រោង SCCRP បានផ្តល់នូវមេរៀនមួយចំនួនដែលគួរពិចារណាក្នុងទស្សនៈនៃការបង្កើនលទ្ធភាពដំណើរការហិរញ្ញប្បទានរបស់អង្គការកសិករ។

## ៣.១. ការវាយតម្លៃលើការប្រើប្រាស់ឥណទាន និងការធ្វើសេចក្តីសម្រេច

ដូចដែលបានរៀបរាប់ខាងលើ ការវាយតម្លៃលើការប្រើប្រាស់ឥណទាន និងដំណើរការផ្តល់ប្រាក់កម្ចីនៅតែមានភាពស្មុគស្មាញ និងចំណាយពេលយូរ ហើយអាចនិយាយបានថានៅតែមានឧបសគ្គច្រើន ដើម្បីអាចឱ្យអង្គការកសិករទទួលបានប្រាក់កម្ចីពីពីធនាគារអភិវឌ្ឍន៍ជនបទ៖

**ការវាយតម្លៃពីដៃគូ**ត្រូវចំណាយពេលវេលាច្រើន ជាពិសេសដោយសារតែអ្នកដាក់ពាក្យស្នើសុំខ្ចីប្រាក់ភាគច្រើនមិនមានឯកសារត្រឹមត្រូវពេញលេញ និងស្របតាមច្បាប់។ កត្តានេះបានផ្សារភ្ជាប់ជាមួយនឹងការប្រែប្រួលថ្មីៗនៃចលនាសហប្រតិបត្តិការនៅប្រទេសកម្ពុជា។ ដំណាក់កាលសាកល្បងនៃភាពជាដៃគូប្រាក់កម្ចីជាមួយធនាគារអភិវឌ្ឍន៍ជនបទបានធ្វើឱ្យសហព័ន្ធអង្គការកសិករយល់ពីស្ថានភាពនេះ ហើយបានដឹកនាំពួកគេឱ្យធ្វើការស្នើសុំទៅនាយកដ្ឋានលើកកម្ពស់សហករណ៍កសិកម្មរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឱ្យផ្តល់ការបណ្តុះបណ្តាលលើឯកសារសហករណ៍កសិកម្មស្របច្បាប់ដល់សមាជិករបស់ខ្លួន។ ធនាគារអភិវឌ្ឍន៍ជនបទផ្ទាល់ក៏បានបង្កើតទម្រង់បែបបទសម្រាប់ឯកសារដែលតែងតែខ្វះខាត ហើយណែនាំដល់មន្រ្តីឥណទានរបស់ខ្លួនឱ្យជួយគាំទ្រទៅដល់សហករណ៍កសិកម្មក្នុងការបំពេញចន្លោះប្រហោងនៅពេលចុះពិនិត្យការអនុវត្ត ដែលនឹងនាំឱ្យមានការកាត់បន្ថយរយៈពេលដំណើរការ។ ទោះបីជាការផ្គត់ផ្គង់ដោយប្រសិទ្ធភាពរបស់ពួកគេនៅមានកម្រិតក៏ដោយ អ្នកផ្តល់ប្រាក់កម្ចីដទៃទៀតដល់អង្គការកសិករ (គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ព្រះពុទ្ធសាសនាសម្រាប់មូលនិធិអភិវឌ្ឍន៍) ក៏មិនពឹងផ្អែកលើឯកសារច្បាប់ ដើម្បីវាយតម្លៃភាពរឹងមាំរបស់ដៃគូដែរ ប៉ុន្តែផ្អែកលើធាតុដែលប្រមូលបាននៅពេលចុះពិនិត្យការអនុវត្ត។

កត្តាមួយទៀតដែលពន្យល់ពីពេលវេលាដែលត្រូវការ ដើម្បីវាយតម្លៃលើការប្រើប្រាស់ប្រាក់កម្ចី គឺថាកសិករខ្នាតតូចៗ និងអង្គការកសិករ គឺជាទីផ្សារថ្មីសម្រាប់ធនាគារអភិវឌ្ឍន៍ជនបទ ហើយថាអង្គការកសិករក៏មានបទពិសោធន៍ថ្មីៗតិចតួចផងដែរ។ នេះជាការចាំបាច់សម្រាប់ធនាគារអភិវឌ្ឍន៍ជនបទក្នុងការវិនិយោគដោយប្រុងប្រយ័ត្នលើចំណេះដឹងរបស់អតិថិជនដើម្បីឱ្យសកម្មភាពនេះអាចចាប់ផ្តើមដោយមានមូលដ្ឋានច្បាស់លាស់មុនពេលកាត់បន្ថយការវិភាគ។

ជាលទ្ធផល ដំណើរការប្រាក់កម្ចីតែងតែត្រូវចំណាយពេលយូរពេកក្នុងការការសម្រេចចិត្តឱ្យប្រាក់ខ្ចីទាន់ពេលវេលាសម្រាប់ការចំណាយនៅក្នុងរដូវកាលនៃសកម្មភាពស្នើសុំ។

**ទ្រព្យបញ្ចាំផ្អែកលើប័ណ្ណកម្មសិទ្ធដីធ្លី ៖** នៅប្រទេសកម្ពុជា តម្រូវការទ្រព្យបញ្ចាំមានកម្រិតខ្ពស់ទាំងក្នុងវិស័យធនាគារ និងក្នុងវិស័យមីក្រូហិរញ្ញវត្ថុ។ ដូច្នេះនេះហាក់ដូចជារឿងធម្មតាចំពោះកសិករដែលថាពួកគាត់តម្រូវឱ្យដាក់ប័ណ្ណកម្មសិទ្ធិដីធ្លីដើម្បីទទួលបានប្រាក់កម្ចី។ សមាជិកក្រុមប្រឹក្សាភិបាលរបស់សហព័ន្ធបានយល់ស្របថា ពួកគេនឹងមិនពេញចិត្តចំពោះការផ្តល់កម្ចីដល់សហករណ៍កសិកម្មដោយគ្មានដាក់ទ្រព្យបញ្ចាំទេ។ ក្នុងបរិបទនេះ ហាក់ដូចជាមិនពិបាកក្នុងការកៀងគរប័ណ្ណកម្មសិទ្ធិដីធ្លីពីសមាជិកក្រុមប្រឹក្សាភិបាល ដើម្បីផ្តល់ទ្រព្យបញ្ចាំសម្រាប់ប្រាក់កម្ចីដែលស្នើសុំឡើយ នៅពេលដែលសហករណ៍កសិកម្មមិនមានដីផ្ទាល់ខ្លួនប្រើប្រាស់ជាទ្រព្យបញ្ចាំ ហើយនេះបង្ហាញពីអត្ថប្រយោជន៍នៃការធ្វើឱ្យប្រាកដថាសមាជិកទាំងនេះត្រូវជាប់ពាក់ព័ន្ធនឹងកម្ចី ហើយកាត់បន្ថយហានិភ័យលើការប្រើប្រាស់ខុសគោលដៅ។ ទោះជាយ៉ាងណាក៏ដោយ នៅតែមានផលជះដល់ពេលវេលាដែលត្រូវការសម្រាប់ការស្នើសុំប្រាក់កម្ចី ព្រោះថាអង្គការកសិករភាគច្រើនត្រូវដកប័ណ្ណកម្មសិទ្ធិដីធ្លីពីសមាជិករបស់ខ្លួន ដើម្បីបំពេញតម្រូវការទ្រព្យបញ្ចាំរបស់ធនាគារអភិវឌ្ឍន៍ជនបទ ដែលធ្វើឱ្យនីតិវិធីនេះកាន់តែមានភាពស្មុគស្មាញឡើង៖ ភាគច្រើន គឺប្តីប្រពន្ធត្រូវចុះហត្ថលេខាលើប័ណ្ណកម្មសិទ្ធិនីមួយៗ ហើយជួនកាលសមាជិកដកប័ណ្ណកម្មសិទ្ធិចាស់របស់ពួកគេចេញក្នុងដំណើរការនេះ ហើយចាំបាច់ត្រូវតែ

ដំណើរការម្តងទៀតជាមួយនឹងប័ណ្ណកម្មសិទ្ធិថ្មី។ លើសពីនេះទៀត ទ្រព្យបញ្ចាំដោយផ្អែកលើប័ណ្ណកម្មសិទ្ធិដីធ្លី តម្រូវឱ្យធនាគារអភិវឌ្ឍន៍ជនបទវាយតម្លៃសេដ្ឋកិច្ចនៃតម្លៃដីធ្លី ដែលតម្រូវឱ្យមានការធ្វើដំណើរទៅដល់កន្លែង (ជាញឹកញាប់ទៅដល់ដីដាច់ស្រយាល និងដីដែលនៅរាយប៉ាយនៅតាមជនបទ) និងដើម្បីវាយតម្លៃនិន្នាការនៃទីផ្សារដីតំបន់នោះ។ ធនាគារអភិវឌ្ឍន៍ជនបទបានលើកឡើងថា ឥឡូវនេះពួកគេបានស្នើសុំឱ្យអង្គការកសិករផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីដែលមិននៅឆ្ងាយពីភូមិដែលអាចជួយកាត់បន្ថយពេលវេលាដែលចាំបាច់សម្រាប់ការវាយតម្លៃផ្ទាល់លើទ្រព្យបញ្ចាំពី ១ ទៅ ២ ម៉ោង ក្នុងប័ណ្ណកម្មសិទ្ធិនីមួយៗ ។

**សមត្ថភាពទាបរបស់អង្គការកសិករ៖** ភាគច្រើននៅប្រទេសកម្ពុជា អង្គការកសិករនៅតែស្ថិតក្នុងដំណាក់កាលដំបូងនៃការអភិវឌ្ឍ និងវិជ្ជាជីវៈភាវូបនីយកម្មរបស់ពួកគេ។ សមត្ថភាពគ្រប់គ្រងនិងផ្នែកគណនេយ្យរបស់ពួកគេតែងតែនៅតែមានកម្រិតនៅឡើយ ដែលធ្វើឱ្យការយល់ដឹងពីហានិភ័យកាន់តែលំបាក ហើយនោះជាកត្តាតំណាងឱ្យហានិភ័យរបស់គ្រឹះស្ថានហិរញ្ញវត្ថុ ។

## ៣.២. អន្តរកម្មជាមួយសហព័ន្ធអង្គការកសិករ

ដូចរៀបរាប់ខាងលើ សហព័ន្ធអង្គការកសិករបានដើរតួជា**ចំណុចប្រទាក់គ្នា**យ៉ាងសំខាន់រវាងធនាគារអភិវឌ្ឍន៍ជនបទ និងសមាជិករបស់ខ្លួនក្នុងការផ្សព្វផ្សាយព័ត៌មាន ការកំណត់អត្តសញ្ញាណអង្គការកសិករដែលមានសិទ្ធិទទួលប្រាក់កម្ចី ផ្តល់ការគាំទ្រផ្នែកបច្ចេកទេសសម្រាប់ដំណើរការដាក់ពាក្យស្នើសុំ និងការផ្តល់បច្ចេកទេស ការគ្រប់គ្រង និងការគាំទ្រអភិបាលកិច្ចក្នុងការអនុវត្តសកម្មភាពនានា (ជួនកាលជាសកម្មភាពថ្មី) ។ ទោះជាយ៉ាងណាក៏ដោយត្រូវតែបញ្ជាក់ថាការគាំទ្រនេះអាចធ្វើទៅបានដោយសារមានការគាំទ្រខាងក្រៅពីគម្រោង SCCRP ដែលមានន័យថា ប្រសិនបើគេសន្មត់ថាសហព័ន្ធនឹងបន្តមុខងារសំខាន់ៗទាំងនេះ មិនត្រឹមតែពួកគេគួរទទួលបានប្រាក់កម្រៃប៉ុណ្ណោះទេ តែថែមទាំងបន្តការគាំទ្រជាក់ស្តែងចំពោះសហព័ន្ធទៀងផង ដរាបណាសហព័ន្ធមិនអាចមានស្វ័យភាពលើបញ្ហានោះ។ រហូតមកដល់ពេលនេះ FAEC និង FCFD បានគិតកម្រៃសេវាតិចតួចគឺ ១% នៃតម្លៃប្រាក់កម្ចីពីសមាជិករបស់ខ្លួនដែលបានស្នើសុំដោយជោគជ័យក្រោមការគាំទ្ររបស់ពួកគេ។ ការផ្តល់កម្ចីដែលនៅមានពេលនោះ គឺមិនគ្រប់គ្រាន់សម្រាប់ការចំណាយនានារបស់សហព័ន្ធទេ ជាពិសេសចំនួនឥណទានដែលមានចំនួនតិចតួច ហើយអត្រាជោគជ័យនៃការដាក់ពាក្យស្នើសុំមានកម្រិតទាបថែមទៀតនៅដំណាក់កាលដំបូង ដោយសារនីតិវិធីនៅក្នុងដំណើរការសាកល្បងរបស់ពួកគេនៅឡើយ ។

ការព្យាករណ៍ហិរញ្ញវត្ថុត្រូវបានធ្វើឡើងដោយផ្អែកលើការវិភាគបទពិសោធន៍សាកល្បងទាក់ទងនឹងភារកិច្ច និងការចំណាយ និងការប៉ាន់ប្រមាណលើកម្ចីដែលបានផ្តល់ជូនម្តង។ ថវិកាសម្រាប់ការអនុវត្តភាពជាដៃគូដោយសហព័ន្ធ ត្រូវបានបង្កើតឡើងដោយមានពីរសម្មតិកម្មផ្សេងៗគ្នា ទាក់ទងនឹងការរៀបចំដែលចាំបាច់ត្រូវធ្វើការវិភាគយ៉ាងស៊ីជម្រៅជាមួយសហព័ន្ធ៖ (១) គ្រប់ប្រតិបត្តិការទាំងអស់ធ្វើឡើងដោយតំណាងខេត្ត (មិនមែនបុគ្គលិក) (២) ប្រតិបត្តិការបំបែកចេញពីគ្នារវាងអ្នកតំណាងខេត្ត និង "អ្នកជំនាញ" ឬបុគ្គលិក ។ ថវិកាសរុបដែលទទួលបានពីសម្មតិកម្មទាំងនេះបានបង្ហាញថា សហព័ន្ធអាចភ្ជាប់អង្គការកសិករចំនួន ៥៩ ទៅធនាគាររយៈពេលជាង ៥ ឆ្នាំ ហើយទទួលបានកម្ចីចំនួន ១៩៥ លើក។ ការរៀបចំដែលបានធ្វើឡើងក្នុងជម្រើសទី ១ តម្រូវឱ្យមានប្រាក់ចំណូលចំនួន ១០០០ ដុល្លារអាមេរិកក្នុងរយៈពេល ៥ ឆ្នាំ រីឯជម្រើសទី ២ តម្រូវឱ្យមានចំនួន ១៥០០០ ដុល្លារអាមេរិក ។ ជម្រើសទី ១ អាចរាប់បញ្ចូលថ្លៃ

SCCRP ▪ កំណត់ត្រាគោលនយោបាយ

ចំណាយប្រាក់កម្រៃ ០,៥% នៃប្រាក់កម្ចីដែលបានផ្តល់ និងទូទាត់សងមកវិញពីលើថ្លៃដែលសមាជិកសហព័ន្ធបានបង់ឱ្យសហព័ន្ធពេលជោគជ័យ ។

**ប្រអប់ទី ៣៖ ប្រព័ន្ធដាក់ពិន្ទុអង្គការកសិករដែលសហព័ន្ធអង្គការកសិករប្រើប្រាស់ និងអត្ថប្រយោជន៍របស់ប្រព័ន្ធនេះដែលគាំទ្រឥណទានដល់អង្គការកសិករ**

FCFD និង FAEC មានលក្ខណៈដូចគ្នាត្រង់ប្រើប្រាស់ប្រព័ន្ធស្រដៀងគ្នាក្នុងការវាយតម្លៃ និងត្រួតពិនិត្យតាមដានលើសមត្ថភាពស្ថាប័ននៃសមាជិករបស់ពួកគេ។ ប្រព័ន្ធនេះត្រូវបានស្គាល់ថាជា "វិធីសាស្ត្រដាក់ពិន្ទុ" ដែលបង្កើតឡើងដោយ NGO AVSF ដែលជាផ្នែកមួយនៃកម្មវិធីគាំទ្រអង្គការកសិករ។ ប្រព័ន្ធត្រួតពិនិត្យតាមដាននេះត្រូវបានគេចាត់ទុកថាជាទ្រព្យសម្បត្តិដែលធនាគារអាចវាយតម្លៃបាន។ សូម្បីតែធនាគារអភិវឌ្ឍន៍ជនបទក៏នៅតែពិចារណាដែរកាលពីឆ្នាំ ២០១៤ ខណៈដែលសហព័ន្ធកំពុងត្រួតពិនិត្យឡើងវិញលើលក្ខណៈវិនិច្ឆ័យដែលបានប្រើប្រាស់។ ប៉ុន្តែមានការបង្ហាញថា ពិន្ទុដែលអង្គការកសិករទទួលបាន ដើម្បីអាចដាក់សំណើសុំខ្ចីប្រាក់ គឺធនាគារអភិវឌ្ឍន៍ជនបទមិនយកមកពិចារណាទុកជាសមាសធាតុមួយដើម្បីសម្រេចចិត្តទេ។ នៅក្នុងដំណាក់កាលសាកល្បងអនុវត្តប្រព័ន្ធធានាកាលពីឆ្នាំ ២០១៦ គឺគម្រោង SCCRP គ្រាន់តែប្រើប្រាស់វិធីសាស្ត្រដាក់ពិន្ទុនេះដើម្បីសម្រេចចិត្តផ្តល់ការធានាលើប្រាក់កម្ចីប៉ុណ្ណោះ។

ការប្រើប្រាស់ប្រព័ន្ធវិធីសាស្ត្រដាក់ពិន្ទុនេះគឺអាចទាក់ទាញចំណាប់អារម្មណ៍ពីធនាគារ (ក្នុងចំណោមប្រភពព័ត៌មានផ្សេងៗទៀត) ប៉ុន្តែនៅទីបំផុត វិធីសាស្ត្រនេះមិនត្រូវពិចារណាលើចំណុចមួយចំនួនដូចជា៖

- លក្ខណៈវិនិច្ឆ័យរបស់ធនាគាគឺមិនចាំបាច់ស្របទៅតាមសហព័ន្ធទេ
- សហព័ន្ធនេះមិនចាំបាច់មានលក្ខណៈរឹងមាំពេកទេ ហើយនឹងមិនចាំបាច់រក្សាពិន្ទុល្អសម្រាប់ឆ្នាំខាងមុខទេ បើការមិនមានការបន្តគាំទ្រពីខាងក្រៅ។
- ឥណទានរបស់អង្គការកសិករមិនត្រូវបានបម្រុងទុកសម្រាប់សមាជិក FAEC និង FCFD ទេ ចំណែកឯអ្នកដាក់ពាក្យស្នើសុំរបស់សហព័ន្ធត្រូវកំណត់ពិន្ទុ ហើយមិនចាំបាច់កំណត់ពិន្ទុជារៀងរាល់ឆ្នាំចំពោះសមាជិក FAEC និង FCFD ទេ។
- ការដាក់ពិន្ទុរបស់សហព័ន្ធអាចមានការយល់ឃើញថាជាស្ថានភាពទំនាស់ផលប្រយោជន៍សម្រាប់សហព័ន្ធអង្គការកសិករ ។

## ៣.៣ យន្តការធានាសាកល្បង

សម្រាប់ការធានាបណ្តោះអាសន្នដែលផ្តល់ផ្ទាល់តាមរយៈគម្រោង SCCRP គឺ**គណៈកម្មាធិការធានា**បានពិនិត្យតែលើការដាក់ពាក្យស្នើសុំខ្ចីប្រាក់ចំនួនពីរលើកប៉ុណ្ណោះ ព្រោះមិនមានការធានាសម្រាប់ឥណទានណាមានរយៈពេលហួសពីខែកញ្ញាឆ្នាំ ២០១៧ ឡើយដោយសារតែគម្រោងត្រូវបញ្ចប់។

ការពិភាក្សាក្នុងគណៈកម្មាធិការធានាគឺនៅមានកម្រិតនៅឡើយ ចំពោះការពិនិត្យលើលក្ខណៈវិនិច្ឆ័យដែលបានបំពេញលើការធានា រួមមានដូចជាការផ្ទៀងផ្ទាត់ពិន្ទុអប្បបរមារបស់អ្នកដាក់ពាក្យស្នើសុំមាន ដែល FAEC ឬ FCFD បាន

វាយតម្លៃ (ផ្អែកលើប្រព័ន្ធវិធីសាស្ត្រដាក់ពិន្ទុ - សូមមើលប្រអប់ទី ៣ នៅទំព័រមុន)។ នៅពេលប្រជុំជាក់ស្តែង ការសម្រេចចិត្តធានាគឺបានធ្វើតែមួយលើកប៉ុណ្ណោះ ហើយមួយលើកទៀតគឺបានធ្វើនៅការប្រជុំតាមអ៊ីម៉ែល។ ដូចនេះ ការសម្រេចចិត្តធានាគឺបានធ្វើឡើងយ៉ាងរហ័ស (តែប៉ុន្មានថ្ងៃប៉ុណ្ណោះ) ប៉ុន្តែការសម្រេចចិត្តនេះត្រូវតែបន្ថែមទៅក្នុងដំណើរការសម្រេចចិត្តឱ្យខ្ចីប្រាក់ និងរួមចំណែកក្នុងរយៈពេលនៃដំណើរការសម្រេចចិត្តទាំងអស់។ ស្របតាមកាលៈទេសៈការធ្វើសកម្មភាពកម្រិតទាប ការបន្តការធានាលក្ខណៈបុគ្គលគឺជារឿងសមហេតុផល។ ប៉ុន្តែវាអាចនឹងចំណាយច្រើនដែលមិនសមហេតុផលទៅលើផ្នែករដ្ឋបាល និងកើនឡើងពេលវេលាច្រើនលើការសម្រេចចិត្តលើការដាក់ពាក្យស្នើសុំមួយចំនួន។ ប្រព័ន្ធធានាលើផលប័ត្រឥណទានអាចត្រូវបានពិចារណាសម្រាប់ប្រាក់កម្ចីមានទំហំតូចជាង ចំណែកឯប្រាក់កម្ចីដែលមានកម្រិតខ្ពស់ជាក់លាក់ និងមានទំហំធំជាងនេះនឹងត្រូវទទួលបានការធានាជាលក្ខណៈបុគ្គល។

នៅក្នុងដំណាក់កាលសាកល្បងនេះ សហព័ន្ធអង្គការកសិករចំនួនពីរ (FAEC និង FCFD) បានចូលរួមនៅក្នុងគណៈកម្មាធិការធានា (មានតែតំណាងសហព័ន្ធប៉ុណ្ណោះ៖ គឺអ្នកស្នើសុំមកពី FAEC ឬ FCFD) ហើយពិន្ទុដែលអ្នកដាក់ពាក្យស្នើសុំទទួលបាន គឺជាផ្នែកមួយនៃលក្ខណៈវិនិច្ឆ័យសម្រាប់ការធានាសិទ្ធិដែលទទួលបាន។ ក្នុងករណីដែលសហព័ន្ធអង្គការកសិករមានការទាក់ទងក្នុងការសម្រេចចិត្តធានាសម្រាប់ប្រាក់កម្ចីពាក់ព័ន្ធនឹងសមាជិករបស់ខ្លួននេះ គឺអាចនឹងត្រូវចាត់ទុកជាកត្តាហានិភ័យមួយដែរ។ ហេតុផលដែលធ្វើដូចនេះគឺមានតាំងពីដំបូង ដោយមានការមើលឃើញថាសហព័ន្ធនឹងរួមចំណែកផ្តល់មូលនិធិផ្ទាល់ខ្លួនក្នុងមូលនិធិធានា ហើយការប្តេជ្ញាចិត្តធានាដោយទុនផ្ទាល់ខ្លួនរបស់ពួកគេជាមធ្យោបាយមួយ ដើម្បីធ្វើឱ្យប្រាកដថាពួកគេជួយអង្គការកសិករឱ្យរៀបចំការដាក់ពាក្យស្នើសុំបានល្អ និងបង្ហាញទៅធនាគារអភិវឌ្ឍន៍ជនបទតែពាក្យស្នើសុំពីអង្គការកសិករដែលអាចជឿទុកចិត្តបានប៉ុណ្ណោះ។ ករណីនេះប្រហែលជាមិនមានជាប់ពាក់ព័ន្ធទេ ប្រសិនបើសហព័ន្ធមិនផ្តល់ដើមទុនផ្ទាល់ខ្លួននៅក្នុងយន្តការធានានេះ។ ប៉ុន្តែ ទោះបីមិនបានដាក់មូលនិធិរបស់ខ្លួនក្នុងការធានានេះក៏ដោយ ក៏សហព័ន្ធនៅតែលើកទឹកចិត្តឱ្យបង្កើតយន្តការកម្ចីដែលមានប្រសិទ្ធភាព និងអាចទុកចិត្តបានតាមរយៈការជ្រើសរើសអតិថិជនល្អៗដើម្បីអាចខ្ចីប្រាក់បាន ដែលនេះជាការរំពឹងទុកដ៏សំខាន់មួយរបស់សមាជិករបស់ពួកគេ។ ការសម្របសម្រួលឱ្យមានលទ្ធភាពទទួលហិរញ្ញប្បទានដោយនិរន្តភាពមានន័យថា បង្កើតទំនុកចិត្តរបស់គ្រឹះស្ថានហិរញ្ញវត្ថុជាដៃគូ និងបង្ហាញទំនុកទុកចិត្តរបស់អង្គការកសិករ ក្នុងនាមជាអ្នកខ្ចីប្រាក់។

ផលជះមួយទៀតដែលពាក់ព័ន្ធនឹងសហព័ន្ធក្នុងការសម្រេចចិត្តធានាគឺ ជួយបន្ថយការសម្ងាត់លើការធានាចំពោះអ្នកខ្ចីប្រាក់។ ជាការពិតណាស់ គោលការណ៍នៃការធានាដោយសម្ងាត់ ជារឿយៗគឺធ្វើឡើងសម្រាប់អតិថិជនដែលមិនចេះអក្សរ ហើយមានតែធនាគារទេ ដែលដឹងពីអត្ថប្រយោជន៍ឥណទាននៃការធានា ប៉ុន្តែមិនមែនអ្នកទទួលផលពីឥណទានដឹងទេ។ គោលការណ៍នេះក៏អនុវត្តផងដែរចំពោះការធានាផលប័ត្រ។ ប្រសិនបើសហព័ន្ធអង្គការកសិករជាប់ពាក់ព័ន្ធដែរ នោះការធានានឹងទំនងជាមិនត្រូវរក្សាការសម្ងាត់ទេ។

# ៤. ការផ្តល់អនុសាសន៍ផ្នែកគោលនយោបាយសម្រាប់ផ្តល់ហិរញ្ញប្បទានដល់អង្គការកសិករ

## ៤.១ ការរក្សា និងបង្កើនទំហំឥណទានរបស់ធនាគារអភិវឌ្ឍន៍ជនបទសម្រាប់អង្គការកសិករគឺជាការចាំបាច់ខ្លាំង

### ៤.១.១. ភាពចាំបាច់ដែលត្រូវបង្ហាញអំពីសក្តានុពលនៃការអភិវឌ្ឍន៍របស់អង្គការកសិករ

អង្គការកសិករតំណាងឱ្យសក្តានុពលអភិវឌ្ឍន៍ និងការពង្រឹងលើជំហរ និងចំណូលរបស់កសិករខ្នាតតូចនៅកម្ពុជា។ កត្តានេះត្រូវបានបង្ហាញយ៉ាងច្បាស់លាស់នៅក្នុងឯកសារស្តីពីគោលនយោបាយ និងយុទ្ធសាស្ត្ររបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ការលើកឡើងបែបនេះមាននៅក្នុងផ្នែកដំបូងនៃរបាយការណ៍នេះ (សូមមើលចំណុច ១.១ និងចំណុច ១.២) ដែលជាប្រភពមួយបញ្ជាក់អំពីការចូលរួមរបស់គម្រោង SCCRP សម្រាប់ការបង្កើតកញ្ចប់ឥណទានរបស់អង្គការកសិករ ដោយឱ្យនៅបន្តសុពលភាព និងច្បាស់លាស់។

លទ្ធភាពដើម្បីទទួលបានហិរញ្ញប្បទាននៅតែជាឧបសគ្គចម្បងសម្រាប់សហករណ៍កសិកម្ម ហើយជាពិសេសអង្គការកសិករ ត្រូវតែទទួលបានការដោះស្រាយ ប្រសិនបើយើងចង់សម្រេចគោលបំណងនៃការអភិវឌ្ឍរបស់ពួកគេ ក្នុងនាមជាភាគីពាក់ព័ន្ធផ្នែកសេដ្ឋកិច្ច និងពាណិជ្ជកម្មនៅក្នុងសង្វាក់តម្លៃកសិផល។

### ៤.១.២. ភាពទាក់ទងនឹងអាណត្តិយ៉ាងជាក់លាក់របស់ធនាគារអភិវឌ្ឍន៍ជនបទ

ជាផ្នែកមួយនៃដំណើរការកំណែទម្រង់ និងការធ្វើប្រសើរឡើងសម្រាប់ធនាគារអភិវឌ្ឍន៍ជនបទដែលគាំទ្រដោយគម្រោង SCCRP គឺមានការបញ្ជាក់ឡើងវិញនូវការបង្ហាញយុទ្ធសាស្ត្រសម្រាប់សកម្មភាពរបស់ធនាគារអភិវឌ្ឍន៍ជនបទដើម្បីគាំទ្រគោលបំណងគោលនយោបាយ។ ធនាគារអភិវឌ្ឍន៍ជនបទមានការកំណត់យ៉ាងច្បាស់លាស់សម្រាប់ដោះស្រាយតម្រូវការហិរញ្ញវត្ថុរបស់ដៃគូឯកជនដែលពាក់ព័ន្ធនៅក្នុងវិស័យកសិកម្ម និងតំបន់ជនបទ ដើម្បីផ្តល់ហិរញ្ញប្បទានដល់សកម្មភាពដែលអាចរួមចំណែកឲ្យសម្រេចបាននូវគោលបំណងគោលនយោបាយ ជាពិសេសពេលដែលតម្រូវការទាំងនេះមិនត្រូវបានដោះស្រាយដោយវិស័យហិរញ្ញវត្ថុឯកជន។

ដោយមានការផ្តល់បទបង្ហាញស្តីពីគោលនយោបាយឆ្ពោះទៅរកការអភិវឌ្ឍសហករណ៍កសិកម្ម និងកត្តាភាពស្ទាក់ស្ទើររបស់ធនាគារពាណិជ្ជ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុក្នុងការផ្តល់ប្រាក់កម្ចីដល់អង្គការកសិករនាពេលបច្ចុប្បន្ននេះ គឺវាពិតជាពាក់ព័ន្ធ ក៏ដូចជាស្របទៅនឹងអាណត្តិរបស់ធនាគារអភិវឌ្ឍន៍ជនបទដែលផ្តួចផ្តើម និងបង្កើតសេវាកម្មផ្តល់ឥណទានសម្រាប់អង្គការកសិករ។ សេវានេះត្រូវបានផ្តួចផ្តើមឡើងជាផ្លូវការកាលពីឆ្នាំ ២០១៦ ដោយមានការគាំទ្រពីគម្រោងនេះ ប៉ុន្តែនៅតែស្ថិតក្នុងដំណាក់កាលសាកល្បង ហើយចំនួនប្រាក់កម្ចី ព្រមទាំងចំនួនទឹកប្រាក់ដែលបានបម្រុងទុកសម្រាប់សហករណ៍កសិកម្មនៅមានកម្រិត។

ធនាគារអភិវឌ្ឍន៍ជនបទបានបង្ហាញពីបំណងបន្តបង្កើនផលប័ត្រឥណទានរបស់ខ្លួនដល់អង្គការកសិករ (ជាមួយគោលបំណងនៃការផ្តល់កម្ចីសរុបទៅអង្គការកសិករចំនួន ២ លានដុល្លារក្នុងឆ្នាំ ២០១៨) ហើយការលើកឡើងនេះចាំបាច់ត្រូវបានលើកទឹកចិត្ត និងគាំទ្រ។ បន្ទាប់មកការពង្រីកបន្ថែមអាចត្រូវបានពិចារណា នៅក្នុងល្បឿនមួយដែលនឹងត្រូវបានកែតម្រូវទៅនឹងកំណើននៃតម្រូវការ និងកម្រិតចង់បានឥណទានរបស់អង្គការកសិករ។ វាអាចធ្វើទៅបាន ដោយស្របជាមួយគោលនយោបាយដើម្បីទាក់ទាញគ្រឹះស្ថានហិរញ្ញវត្ថុដទៃទៀតទៅកាន់ទីផ្សាររបស់អង្គការកសិករ។

## ៤.២. អំពីលក្ខខណ្ឌ និងម៉ូដែលផ្តល់ឥណទានទៅឲ្យអង្គការកសិករ

### ៤.២.១. អត្រាការប្រាក់៖ ពិចារណាអំពីវិធីកាត់បន្ថយអត្រាការប្រាក់នៃឥណទានដល់អង្គការកសិករ

ធនាគារអភិវឌ្ឍន៍ជនបទបរៀបចំឱ្យមានការផ្តល់ឥណទានដល់អង្គការកសិករក្នុងអត្រាការប្រាក់ប្រហែល ១០ ភាគរយ ក្នុងមួយឆ្នាំ (សម្រាប់ប្រាក់កម្ចីជាប្រាក់ដុល្លារអាមេរិក)។ បច្ចុប្បន្ន ការផ្តល់នេះប្រហែលជាការផ្តល់ឥណទានដ៏ល្អបំផុត ដែលអង្គការកសិករអាចទទួលបាន។ ប៉ុន្តែអត្រានេះនៅមានកម្រិតលើសខ្លាំងពីអត្រាដែលភាគីពាក់ព័ន្ធដទៃទៀត (ដូច ជាម្ចាស់រោងម៉ាស៊ីនកិនស្រូវ) អាចទទួលបានពីវិស័យធនាគារ។ ម្យ៉ាងទៀត (ពីទស្សនៈវិស័យរបស់ថ្នាក់ដឹកនាំធនាគារ និងទស្សនៈវិស័យខាងសេដ្ឋកិច្ច) នេះជារឿងងាយយល់បំផុត ដែលជាទូទៅបរិមាណនៃប្រាក់កម្ចីមានកម្រិតតិចជាង យ៉ាងច្រើន បើធៀបទៅនឹងប្រាក់កម្ចីដែលបានផ្តល់ឲ្យរោងម៉ាស៊ីនកិនស្រូវ ឬក្រុមហ៊ុនកសិឧស្សាហកម្ម ដោយហេតុថា ដំណើរការនៃកម្ចីដែលផ្តល់ឲ្យនេះ រួមបញ្ចូលទាំងការចំណាយលើការចុះទៅត្រួតពិនិត្យទីតាំងរោងម៉ាស៊ីនកិនស្រូវ ឬ ក្រុមហ៊ុនផ្ទាល់ដើម្បីជួបជាមួយអង្គការកសិករ ហើយធនាគារប្រហែលជាប៉ាន់ស្មានថាហានិភ័យជាមួយអង្គការកសិករ នេះមានកម្រិតខ្ពស់ជាង។ ប៉ុន្តែបើក្រឡេកមើលទិដ្ឋភាពម្ខាងទៀត ប្រសិនបើគោលបំណង គឺដើម្បីពង្រឹងអំណាចនៃការ ចរចា និងការប្រកួតប្រជែងរបស់ក្រុមអង្គការកសិករ ភាពខុសគ្នានៃការផ្តល់ប្រាក់កម្ចីនេះអាចនាំឲ្យអង្គការកសិករបន្ត មានគុណវិបត្តិនៃការប្រកួតប្រជែង។ អត្រាការប្រាក់ខ្ពស់ដែលធនាគារអភិវឌ្ឍន៍ជនបទផ្តល់ដល់អង្គការកសិករគឺត្រូវតែ ពិចារណា។ ប៉ុន្តែប្រសិនបើជាការផ្តល់ឥណទាននៅក្នុងកម្រិតសមរម្យសម្រាប់អង្គការកសិករគឺជាគោលបំណងគោល នយោបាយ នោះការផ្តល់ធនបន្ថែមចំពោះធនាគារអភិវឌ្ឍន៍ជនបទ អាចត្រូវបានពិចារណាដើម្បីឱ្យធនាគារអាចកាត់ បន្ថយអត្រាការប្រាក់បន្ថែមទៀតលើកម្ចីទាំងនេះ ពេលដែលវាគ្របដណ្តប់លើការចំណាយប្រតិបត្តិការរបស់ខ្លួន។ ក្នុង ករណីនេះ មានមតិលើកឡើងផ្សេងគ្នាដូចជា ម្ខាង ១) បានចាត់ទុកថា ធនាគារអភិវឌ្ឍន៍ជនបទ ត្រូវតែបន្តទៅឆ្ងាយ ជាងអ្វីដែលគ្រឹះស្ថានហិរញ្ញវត្ថុឯកជនអាចធ្វើបាន ព្រោះវាជាទិសដៅ និងគោលនយោបាយសាធារណៈរបស់ធនាគារ។ ហើយម្ខាងទៀត ២) បានលើកឡើងថា អ្នកទាំងឡាយណាដែលធ្វើឲ្យមានការប្រែប្រួលទីផ្សារគួរត្រូវបានជៀសវាង ហើយការផ្តល់ធនគួរតែត្រូវបានពិចារណា ចំពោះតែក្នុងរយៈពេលខ្លី ឬ អន្តរកាលនិងបើកចំហដោយស្មើភាពគ្នាចំពោះ គ្រឹះស្ថានហិរញ្ញវត្ថុសាធារណៈ និងឯកជន។ ជម្រើសនេះនឹងតម្រូវឱ្យមានការសម្រេចចិត្តច្បាស់លាស់ និងបែងចែក ថវិកាជាក់លាក់របស់រាជរដ្ឋាភិបាល (ដែលមិនបានស្វែងអំពីករណីធនាគារអភិវឌ្ឍន៍ជនបទបានផ្តល់កម្ចីឥណទានដែល ត្រូវបានគេរំពឹងថានឹងចំណាយលើសកម្មភាពទូទៅរបស់ខ្លួនដល់អង្គការកសិករនោះទេ) ។ ជាទូទៅវាត្រូវបានរំលឹកនៅ ទីនេះថា ការផ្តល់អត្រាការប្រាក់គឺជាឧបករណ៍មួយដែលត្រូវការឱ្យមានការប្រើប្រាស់ដោយប្រុងប្រយ័ត្នដើម្បីជៀសវាង ផលប៉ះពាល់អវិជ្ជមានណាមួយ។ ដើម្បីឱ្យពួកគេឈានដល់គោលដៅគោលនយោបាយរបស់ពួកគេបាន ពួកគេត្រូវ មានគោលដៅច្បាស់លាស់ទាក់ទងនឹងអត្ថប្រយោជន៍ផ្សេងៗ ក៏ដូចជាគោលបំណង។ នៅទីនេះអ្វីដែលជាការពិតនោះ គឺ ការដែលរោងម៉ាស៊ីនកិនស្រូវទទួលបានអត្ថប្រយោជន៍ពីការផ្តល់អត្រាការប្រាក់គឺជាការតស៊ូមតិមួយដែលជំរុញដល់ ការផ្តល់ឱ្យអង្គការកសិករនូវការគាំទ្រស្រដៀងគ្នា។

### ៤.២.២. វត្ថុបញ្ចាំ និងការធានា៖ របៀបទទួលបានប្រាក់កម្ចីដោយងាយស្រួលជាបន្ត

នៅក្នុងករណីភាគច្រើន អង្គការកសិករមិនមានដីដែលជាកម្មសិទ្ធិផ្ទាល់ខ្លួនទេ ហើយត្រូវទាមទារឲ្យសមាជិករបស់ខ្លួនធ្វើការសន្យាដាក់ប្លង់ដីជាវត្ថុបញ្ចាំ។ មូលនិធិធានារបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងអនុញ្ញាតឲ្យមានការកាត់បន្ថយកម្រិតនៃវត្ថុបញ្ចាំចំនួន ៥០ % ។ ប៉ុន្តែទោះបីជាយ៉ាងនេះក្តី គឺនៅតែជាផលវិបាកសម្រាប់អង្គការកសិករក្នុងការប្រមូលវត្ថុបញ្ចាំឲ្យបានគ្រប់គ្រាន់។ ជាមួយគ្នានេះដែរ នៅក្នុងករណីខ្លះ បញ្ហានេះត្រូវបានសង្កេតឃើញថា មានភាពលម្អៀងនៅក្នុងម៉ូដែលអាជីវកម្មរបស់អង្គការកសិករ ដោយសារតែសមាជិកដែលត្រូវបានឲ្យធ្វើកិច្ចសន្យាដោយដាក់ប្លង់ដីរបស់ពួកគេ គឺរំពឹងទុកនូវសំណងហិរញ្ញវត្ថុមកវិញ។ នេះមិនមែនជាបញ្ហាទេ ប្រសិនបើកិច្ចសន្យានេះមិនត្រូវបានបញ្ជាក់ និងធ្វើឡើងប្រកបដោយសុចរិតភាពជាមួយនឹងអង្គការកសិករ (ឧទាហរណ៍៖ អង្គការកសិករមួយចំនួនបានកំណត់ថា ១០ % នៃប្រាក់ចំណេញដែលបានមកពីសកម្មភាពផ្តត់ផ្គង់ហិរញ្ញវត្ថុដោយឥណទាន នឹងសងសមាជិកទាំងឡាយដែលបានយល់ព្រមដាក់ប្លង់ដីរបស់ពួកគេក្នុងកិច្ចសន្យានោះ)។ ប៉ុន្តែក្នុងករណីផ្សេងទៀត សារៈសំខាន់របស់ម្ចាស់ដីនៅក្នុងការគ្រប់គ្រងសកម្មភាព និងភាពសមរម្យនៃប្រាក់ចំណូលដែលបានបង្កើត គឺមិនសមាមាត្រគ្នា ហើយសកម្មភាពនេះ ប្រែក្លាយទៅជាអាជីវកម្មឯកជនរបស់សមាជិកមួយចំនួន ជាជាងអាជីវកម្មរួមពិតប្រាកដរបស់អង្គការកសិករ។

ជម្រើសច្នៃប្រឌិតផ្សេងទៀតក្នុងការកាត់បន្ថយលក្ខខណ្ឌតម្រូវនៃវត្ថុបញ្ចាំក្នុងរូបភាពជាប្លង់ដី នឹងរួមចំណែកក្នុងការកាត់បន្ថយហានិភ័យ មិនថាតាមរយៈយន្តការធានាទី ២ (ជម្រើសមួយដែលត្រូវបានវិវត្តន៍ គឺជាមូលនិធិធានា ដែលគ្រប់គ្រងដោយសហព័ន្ធអង្គការកសិករ និងដែលអាចគ្របដណ្តប់ផ្នែកបន្ថែមនៃកម្ចីបាន) ឬតាមរយៈការលើកទឹកចិត្តអង្គការកសិករឲ្យដាក់ប្រាក់ជាការធានា (ដែលអាចត្រូវបានចូលរួមចំណែកកាន់តែងាយស្រួលជាងមុនពីសំណាក់សមាជិកជាច្រើនតាមរយៈការរួមចំណែកដ៏គួរឲ្យកត់សម្គាល់នៅក្នុងភាគហ៊ុនដើមទុនរបស់សហករណ៍កសិកម្ម)។ ប៉ុន្តែកិច្ចពិភាក្សាជាមួយអ្នកតំណាងអង្គការកសិករបានបង្ហាញថា វិធីសាស្រ្តនៃការយកប្រាក់កម្ចីមកវិនិយោគ (សមាមាត្រចំនួនប្រាក់កម្ចី/ចំនួនប្រាក់បញ្ញើ) ត្រូវមានភាពគ្រប់គ្រាន់ដើម្បីធ្វើឲ្យប្រតិបត្តិការមានភាពទាក់ទាញ។ វាហាក់បីដូចជា ទឹកប្រាក់ចំនួន ២០ %នៃចំនួនកម្ចីសរុប ពិតជាមានភាពអតិបរមាខ្លាំង ដែលអង្គការកសិករអាចទទួលយកបាន ។

ជាការពិតដែលអង្គការកសិករជាច្រើន បានបង្កើតសកម្មភាពកម្ចីសម្រាប់សមាជិករបស់ខ្លួនដែលមានតម្រូវការខ្ពស់ និងមិនពេញចិត្តនឹងមូលនិធិដែលមានស្រាប់ ដែលជាញឹកញាប់ទទួលបានផលចំណេញច្រើនជាងសកម្មភាពពាណិជ្ជកម្មនៅក្នុងផលិតកម្មនៃផលិតផលកសិកម្មសម្រាប់ផ្គត់ផ្គង់អតិថិជន ដូច្នេះ វាបង្កើតឲ្យមានសំណងជាច្រើននៃអ្នកបញ្ញើ (១,៥ ភាគរយ ទៅ ២,៥ ភាគរយ ក្នុងមួយខែ) ធ្វើឲ្យឆន្ទៈរបស់ពួកគេនៅមានកម្រិតក្នុងការចូលរួមបន្ថែមដើមទុនរបស់ខ្លួនផ្ទាល់នៅក្នុងសកម្មភាពពាណិជ្ជកម្ម។

### ៤.២.៣. ការផ្តល់ឥណទានដល់អង្គការកសិករ (១) គឺបង្រួបបង្រួមភាពជាដៃគូជាមួយសហព័ន្ធអង្គការកសិករ

ចាប់ពីឆ្នាំ២០១៦ ក្រោយពេលធនាគារអភិវឌ្ឍន៍ជនបទបានអនុម័តគោលនយោបាយឥណទានសម្រាប់អង្គការកសិករ នោះភាពជាដៃគូក្រៅផ្លូវការត្រូវបានអនុវត្តរវាងធនាគារអភិវឌ្ឍន៍ជនបទ និងសហព័ន្ធអង្គការកសិករចំនួន ០២ (FAEC និង FCFD)។ សហព័ន្ធអង្គការកសិករបានរួមចំណែកក្នុងការផ្សព្វផ្សាយនូវការផ្តល់ជូនឥណទានពីធនាគារអភិវឌ្ឍន៍ជនបទទៅកាន់សមាជិករបស់ខ្លួន និងបានជួយជ្រោមជ្រែងសមាជិករបស់ខ្លួនក្នុងការរៀបចំគម្រោងពាណិជ្ជកម្ម និងពាក្យសុំ ព្រមទាំងនាំពាក្យត្រឡប់ទៅកាន់ធនាគារអភិវឌ្ឍន៍ជនបទផងដែរ ។

ភាពជាដៃគូនេះស័ក្តសមនឹងត្រូវបានសម្របសម្រួល និងបង្កើតជាទម្រង់ ហើយអាចផ្តល់ផលប្រយោជន៍សម្រាប់ភាគីទាំងពីរពិតប្រាកដមែន ។ កាលពីខែ វិច្ឆិកា ឆ្នាំ២០១៧ គម្រោង SCCRP បានបង្កើតបេសកកម្មចុងក្រោយនៃហិរញ្ញវត្ថុអភិវឌ្ឍន៍ HORUS ដែលត្រូវបានផ្តោតដ៏គួរឲ្យកត់សម្គាល់ ស្តីពីការធ្វើសេចក្តីព្រាងនៃទម្រង់អនុស្សរណៈនៃការយោគយល់គ្នា ដែលអាចត្រូវបានចុះហត្ថលេខារវាងសហព័ន្ធអង្គការកសិករ និងធនាគារអភិវឌ្ឍន៍ជនបទ ដើម្បីពង្រឹងភាពជាដៃគូនេះបន្ថែមទៀត ។

ធនាគារអភិវឌ្ឍន៍ជនបទបានលើកទឹកចិត្តឲ្យចូលរួមក្នុងការអភិវឌ្ឍន៍ទម្រង់នេះ ហើយមិនគួរឲ្យតម្លៃទាបចំពោះភាពជាដៃគូនេះទេ។ សហព័ន្ធអង្គការកសិករអាចជាអ្នកណែនាំពាណិជ្ជកម្មដ៏មានប្រសិទ្ធភាពសម្រាប់ធនាគារ និងទទួលស្គាល់ចំពោះចំណេះដឹងដែលសមាជិករបស់ស្ថាប័នមាន ហើយសហព័ន្ធនេះអាចជាកត្តាកាត់បន្ថយហានិភ័យឥណទានដោយឡែកប្រសិនបើលក្ខខណ្ឌនៃភាពជាដៃគូនេះ រួមមានការលើកទឹកចិត្តសម្រាប់សហព័ន្ធមិនត្រឹមតែស្តីអំពីតម្លៃនៃផលប័ត្រឥណទានប៉ុណ្ណោះទេ ប៉ុន្តែក៏ស្តីអំពីគុណភាពនៃផលប័ត្រនេះផងដែរ (ដែលជាករណីនៅក្នុងលក្ខខណ្ឌដែលត្រូវបានលើកឡើងនៃអនុស្សរណៈនៃការយោគយល់គ្នាដែលបង្កើតដោយ HORUS) ។

សហព័ន្ធអង្គការកសិករក៏គួរមានការជួយជ្រោមជ្រែងក្នុងការបង្កើនសមត្ថភាពរបស់ខ្លួនផងដែរ ដើម្បីអនុវត្តតួនាទីរបស់ខ្លួននៅក្នុងភាពជាដៃគូនេះ ហើយដើម្បីបង្កើនសមត្ថភាពក្នុងការបម្រើសេវាឲ្យអង្គការកសិករ។ ធាតុផ្សំមួយនៃការកាត់បន្ថយហានិភ័យដ៏សំខាន់នៅក្នុងហិរញ្ញវត្ថុកសិកម្ម ដែលមានកសិករធុនតូច និងស្ថាប័នជាគោលដៅ គឺជាការផ្តល់ជូនជំនួយទៅកាន់អ្នកខ្ចី ដើម្បីដឹកនាំប្រកបដោយជោគជ័យ និងគ្រប់គ្រងសកម្មភាពរបស់ពួកគេប្រកបដោយប្រសិទ្ធភាព។ សហព័ន្ធមានតួនាទីដ៏សំខាន់ ប៉ុន្តែទាមទារឲ្យមានជំនួយតាមស្ថាប័ន (ការកសាងសមត្ថភាព និងធនធានមនុស្ស) ដើម្បីអនុវត្តឲ្យកាន់តែមានប្រសិទ្ធភាពជាងមុន (មើលលេខ ៤.៣. ទំព័របន្ទាប់)។

### ៤.២.៤. ការចែកចាយឥណទានដល់អង្គការកសិករ (២) គឺសំឡឹងឃើញបណ្តាញចែកចាយផ្សេងទៀត

ខណៈដែលភាពជាដៃគូជាមួយសហព័ន្ធអង្គការកសិករ ត្រូវបានចាត់ទុកថាជាមធ្យោបាយដ៏មានតម្លៃមួយក្នុងការបង្កើតទំនាក់ទំនងរវាងធនាគារអភិវឌ្ឍន៍ជនបទ និងអង្គការកសិករ នោះគឺមិនគួរប្រើភាពជាដៃគូនេះជាបណ្តាញទូលំទូលាយក្នុងការចែកចាយឥណទានទៅអង្គការកសិករទេ។ ស្របពេលជាមួយគ្នានេះដែរ ធនាគារអភិវឌ្ឍន៍ជនបទ គួរតែទទួលបានការលើកទឹកចិត្តក្នុងការបង្កើត និងអនុវត្តវិធីសាស្ត្រផ្សេងៗ ដើម្បីទាក់ទងជាមួយអង្គការកសិករនៅតាមខេត្តនានាក្នុងប្រទេស។ ការបង្កើត "អង្គភាពចល័ត" របស់ធនាគារអភិវឌ្ឍន៍ជនបទក្នុងពេលថ្មីៗនេះ គឺជាចំណែកនៃយុទ្ធសាស្ត្រមួយដើម្បីបង្កើតការផ្សព្វផ្សាយទៅកាន់អង្គការកសិករដែលជាអតិថិជនមានសក្តានុពល។

វិធីផ្សេងទៀតក៏អាចយកមកពិចារណាដែរ ដូចជាការចាត់តាំងស្ថាប័នផ្សេងទៀតឱ្យដើរតួនាទីជាភ្នាក់ងាររបស់ធនាគារអភិវឌ្ឍន៍ជនបទជាដើម។ ចំណុចសំខាន់នៃវិធីនេះ គឺការប្រើប្រាស់បណ្តាញរបស់គ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗឱ្យមកផ្តល់សេវាកម្មដល់ក្រុមអតិថិជននៅតំបន់ដាច់ឆ្ងាយៗពីគ្នា ដែលធនាគារមានការលំបាកក្នុងការផ្តល់សេវាកម្មដោយផ្ទាល់អាស្រ័យដោយបណ្តាញធនាគារនៅមានកម្រិត។ ទោះជាយ៉ាងណាក្តី ភាពអាចទៅរួច និងភាពពាក់ព័ន្ធនៃជម្រើសនេះមិនទាន់ត្រូវបានគេបញ្ជាក់នៅឡើយ ដោយសារតែគ្រឹះស្ថានហិរញ្ញវត្ថុដែលបានធ្វើវិមជ្ឈការ អាចនឹងមានការស្ទាក់ស្ទើរក្នុងការចូលរួមក្នុងភាពជាដៃគូប្រភេទនេះ ដោយផ្អែកលើហេតុផលខុសៗគ្នាដូចជា៖ (១) ពួកគេអាចនឹងមិនចង់ចែកចាយកម្ចីរបស់ធនាគារអភិវឌ្ឍន៍ជនបទក្នុងអត្រាការប្រាក់ទាបជាងការប្រាក់របស់ពួកគេផ្ទាល់ (២) ពួកគេអាចនឹងមិន

ចង់មានឈ្មោះពាក់ព័ន្ធនឹងមុខមាត់ធនាគាររដ្ឋ ដែលប្រឈមនឹងហានិភ័យខ្ពស់នៃការមិនសងត្រលប់មកវិញដោយសារមុខមាត់រដ្ឋ។ ទោះជាមានការអនុវត្តភាពជាដៃគូក៏ដោយ ហានិភ័យនៃការកើនឡើងហានិភ័យនៅតែមាន ប្រសិនបើគ្រឹះស្ថានហិរញ្ញវត្ថុគ្រាន់តែដើរតួរជាអ្នកចែកចាយ មិនគួរមើលស្រាលទេ។

ជម្រើសមួយទៀតនៅក្នុងការលើកស្ទួយបណ្ដាញជនបទដ៏ធំ ដែលមានស្រាប់នៅក្នុងវិស័យ ហិរញ្ញវត្ថុនៃប្រទេសកម្ពុជាសម្រាប់ការផ្តល់កម្ចីដល់អង្គការកសិករ គឺជាការទាក់ទាញគ្រឹះស្ថានហិរញ្ញវត្ថុដែលធ្វើវិមជ្ឈការមកកាន់ក្រុមអតិថិជននេះ។ គេអាចព្យាយាមធ្វើវាបានតាមរយៈការគាំទ្រសមស្រប ដែលរួមមានការផ្តល់ហិរញ្ញប្បទានដែលមានអត្រាការប្រាក់ទាប ដែលអាចពាំនាំមកជាមួយនូវអ្វីដែលស្រដៀងគ្នាដែរ ក្នុងលក្ខខ័ណ្ឌនៃការបន្ថយការអត្រាការប្រាក់សម្រាប់អតិថិជន។ ធនាគារអភិវឌ្ឍន៍ជនបទ ក៏កំពុងនឹងពិចារណាលើការបង្កើតសាខានៅតាមខេត្តផងដែរ ដែលប្រការនេះនឹងជួយបង្កើតសមត្ថភាពរបស់ធនាគានេះយ៉ាងខ្លាំងលើការទំនាក់ទំនងទៅដល់អង្គការកសិករ។ ក៏ប៉ុន្តែ នេះគឺជាគោលបំណងរយៈពេលវែង ហើយទំនងជាមិនអាចនឹងសម្រេចបានក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខឡើយ។

## ៤.៣. បង្កើត និងអនុវត្តកម្មវិធីគាំទ្រសម្រាប់អង្គការកសិករក្នុងការបំពេញតម្រូវការហិរញ្ញប្បទាន

ត្រូវតែទទួលស្គាល់ថាសមត្ថភាពគ្រប់គ្រងរបស់អង្គការកសិករនៅកម្ពុជានៅមានកម្រិតនៅឡើយ។ ការអភិវឌ្ឍលទ្ធភាពទទួលបានឥណទានរបស់អង្គការកសិករគឺជាធាតុផ្សំដ៏សំខាន់មួយ ដើម្បីចូលរួមចំណែកក្នុងការពង្រឹងការអភិវឌ្ឍរបស់ពួកគេ និងពង្រឹងតួនាទីរបស់កសិករខ្នាតតូចនៅក្នុងខ្សែសង្វាក់ផលិតកម្មកសិកម្ម។ ត្រឹមតែប៉ុណ្ណឹង គឺពុំគ្រប់គ្រាន់ក្នុងការធានាបាននូវការអភិវឌ្ឍសហករណ៍កសិកម្ម ឬអង្គការកសិករនៅក្នុងប្រទេសឡើយ។

កម្មវិធីកសាងសមត្ថភាពអង្គការកសិករទូលំទូលាយ គឺពិតជាសំខាន់ណាស់សម្រាប់ដំណើរការជាមួយនឹងការកសាងសមត្ថភាពអង្គការកសិករក្នុងការបង្កើត និងអនុវត្តសកម្មភាពសមូហភាព ព្រមទាំងក្លាយជាភាគីពាក់ព័ន្ធដែលកាន់តែមានសម្ថភាព និងគួរឱ្យជឿជាក់នៅក្នុងសង្វាក់ផលិតកម្មកសិកម្ម។ កម្មវិធីខ្លះកំពុងតែដំណើរការ (ទ្រទ្រង់ដោយដៃគូអភិវឌ្ឍន៍ផ្សេងៗ និងសំដៅខ្សែសង្វាក់តម្លៃច្បាស់លាស់និង/ឬខេត្តជាក់លាក់) ដែលរួមបញ្ចូល (ឬអាចរួមបញ្ចូល) សកម្មភាពសាងសមត្ថភាពសម្រាប់អង្គការកសិករ។

គេអាចស្រាវជ្រាវលើការរៀបចំកម្មវិធីបានកាន់តែទូលំទូលាយ និងទូទាំងប្រទេស ដែលផ្តោតលើការកសាងសមត្ថភាពនៃការអភិវឌ្ឍជំនួញរបស់អង្គការកសិករ (ហើយអាចនឹងត្រូវរួមបញ្ចូលក្នុងការបង្កើតគម្រោងក្រោយៗផងដែរ) ដោយភ្ជាប់ជាមួយនឹងគោលដៅបង្រួបបង្រួម និងទ្រទ្រង់ឱ្យអស់ពីលទ្ធភាពនូវយន្តការលក្ខណៈស្ថាប័នដែលគ្រប់ដណ្តប់លើតម្រូវការសំខាន់ៗរបស់អង្គការកសិករដូចជា៖

- បន្តគាំទ្រកសិករ និងអង្គការកសិករសម្រាប់ពង្រឹងសមត្ថភាពរបស់ពួកគេក្នុងការបង្កើតគម្រោងជំនួញ ការគ្រប់គ្រងថវិកា និងចំណេះដឹងមូលដ្ឋានលើហិរញ្ញវត្ថុ (ការធ្វើគម្រោង និងគ្រប់គ្រងលំហូរសាច់ប្រាក់ ដើម្បីបង្កើនការប្រើប្រាស់ឥណទាន និងទំហំប្រាក់សន្សំ) ដោយមានគោលដៅអភិវឌ្ឍន៍ការគ្រប់គ្រង និងពង្រឹងភាពគួរឱ្យជឿជាក់របស់ពួកគេទៅកាន់គ្រឹះស្ថានហិរញ្ញវត្ថុ។

- លទ្ធភាពទទួលបានការប្រើប្រាស់ប្រព័ន្ធធនាគារក៏អាស្រ័យលើសមត្ថភាពរបស់កសិករ និងអង្គការកសិករក្នុងការផលិតព័ត៌មានដែលទុកចិត្តបានអំពីសេដ្ឋកិច្ចចិញ្ចឹមជីវិត ដំណើរការធ្វើកសិកម្ម និងគម្រោងសមូហភាព ជាដើមដែរ។
- ដំណើរការទ្រទ្រង់ក្នុងរយៈពេលវែងដូចនេះក៏អាចអនុវត្តជាមួយ ឬអនុវត្តដោយសហព័ន្ធអង្គការកសិករបានដែរ ដោយមានការទ្រទ្រង់រចនាសម្ព័ន្ធហិរញ្ញវត្ថុពីសមត្ថកិច្ចរដ្ឋ និង/ឬគម្រោងនានា។

ប្រសិនបើមានការបង្កើតឡើងកម្មវិធីទ្រទ្រង់នេះ នោះការកសាងសមត្ថភាពអង្គការកសិករ និងកម្មវិធីគាំទ្រនោះអាចផ្សារភ្ជាប់ដោយផ្ទែកជាមួយឥណទានរបស់ធនាគារអភិវឌ្ឍជនបទនឹងអង្គការកសិករ៖ ប្រការដែលអង្គការកសិករទទួលការបង្ហាត់បង្ហាញ/ទ្រទ្រង់ដើម្បីអភិវឌ្ឍសកម្មភាពអាជីវកម្មរបស់ខ្លួន អាចត្រូវចាត់ទុកថា ជាកត្តាកាត់បន្ថយហានិភ័យដែលអាចកត់សម្គាល់បានក្នុងស្ថានភាពប្រសើរឡើងនៃការទទួលបានកម្ចី (រង្វាយតម្លៃហានិភ័យទាបអាចជួយឱ្យមានការទាមទាររបស់បញ្ចាំកម្ចីទាប និង/ឬអត្រាការប្រាក់ទាបជាងមុន)។ សរុបមក គឺជួយដល់ការធ្វើឱ្យសហករណ៍កសិកម្ម និងអង្គការកសិករប្រសើរឡើង និងបង្កើនភាពជឿជាក់ ព្រមទាំងជំនឿចិត្តនៃធនាគារអភិវឌ្ឍន៍ជនបទ (និងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងទៀតជាបន្តបន្ទាប់) ហើយចុងក្រោយ បង្កើនចំនួនអង្គការកសិករ "ដែលមានលទ្ធភាពប្រើប្រាស់ធនាគារ" និងទីផ្សារមានសក្តានុពល ដែលអង្គការទាំងនេះជាតំណាងសម្រាប់គ្រឹះស្ថានហិរញ្ញវត្ថុ។

SCCRP ▪ កំណត់ត្រាគោលនយោបាយ